**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ
-លេខ: ២២៩ "វ"
-ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០
-សំណុំរឿងព្រហ្មទណ្ឌលេខ៨០១១
ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៩
-ស៊ើបសួរលេខ៥៤១៧
ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩
-ជំនុំជម្រះលេខ៥០៦៦
ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង ០៨ និង០០នាទីព្រឹកនៅសាលសវនាការទី៣ដោយមានសមាសភាព៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោកស្រី [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

-លោកស្រី [redacted] សមាជិកក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] សមាជិកក្រុមប្រឹក្សាជំនុំជម្រះ

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជ[redacted]លើសំណុំរឿងព្រហ្មទណ្ឌលេខ ៨០១១ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ

១.ឈ្មោះ [redacted] ភក្តី ហៅ អ៊ុយ ភេទប្រុស កើតឆ្នាំ២០០២ ជាតិខ្មែរ មុខរបរ កម្មករសំណង់ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្ន នៅភ[redacted] ខេត្តកណ្តាល នៅលីវ ឪពុកឈ្មោះ [redacted] ទូច "ស្លាប់" ម្តាយឈ្មោះ [redacted] គុង "រស់" ជានីតិជន ទោសពីមុន គ្មាន ។

-ឃុំខ្លួនតាមដីកាបង្គាប់លេខ ១៣៣៩១ "ញ" ដ.ឃ.ដ ចុះថ្ងៃទី១៩-១១-២០១៩ ។

២.ឈ្មោះ [redacted] ធារ៉ាត់ ហៅ អ៊ុយ ភេទប្រុស អាយុ កើតឆ្នាំ២០០១ ជាតិខ្មែរ មុខរបរ កម្មករសំណង់ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្ន នៅភ[redacted] ខេត្តកណ្តាល នៅលីវ ឪពុកឈ្មោះ [redacted] ស៊ីន "រស់" ម្តាយឈ្មោះ [redacted] សាវង់ "រស់" ជានីតិជន ទោសពីមុន គ្មាន ។

-ឃុំខ្លួនតាមដីកាបង្គាប់លេខ ១៣៣៩០ "ញ" ដ.ឃ.ដ ចុះថ្ងៃទី១៩-១១-២០១៩ ។

មេធាវី [redacted] ការពារសិទ្ធិឲ្យជនជាប់ចោទ ។

ពីបទ ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចខ្ទមទុកចោល ភូមិដើមចាន់ សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**អង្គហេតុនៃរឿងមានដូចតទៅ**



Scanned with CamScanner

-កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង ១៨ និង០០នាទីយប់ សមត្ថកិច្ចប៉ុស្តិ៍ច្បារអំពៅ២ បានល្បាតក្នុងមូលដ្ឋានដល់ចំណុចខ្ទប់ចាស់ទុកចោលផ្លូវលំ ភូមិដើមចាន់ សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ បានប្រទះឃើញមនុស្សពីរនាក់មានឈ្មោះ [redacted] ភក្តី ហៅ អ៊ុយ និងឈ្មោះ [redacted] ធារ៉ាត់ នៅទីនោះដោយមានការសង្ស័យសមត្ថកិច្ចបានត្រួតពិនិត្យឃើញឧបករណ៍ជក់គ្រឿងញៀនមួយកំប្លេរ បន្ទាប់មកសមត្ថកិច្ចក៏ឃាត់ខ្លួន រួមទាំងវត្ថុតាងយកមកសាកសួរ និងធ្វើតេស្តស្វែងរកសារធាតុញៀនបង្ហាញលទ្ធផលវិជ្ជមាននៅអធិការដ្ឋាននគរបាលខណ្ឌច្បារអំពៅ រួចបង្កសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជ-ធានីភ្នំពេញ ។

-បានឃើញ៖របាយការណ៍បញ្ជូនលេខ ២៤១/១៩ ដ.អ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលខណ្ឌច្បារអំពៅ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

-បានឃើញ៖ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ៥៤៦០ អ.យ.ច ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ៖ដីកាសន្និដ្ឋានស្ថាពរលេខ៥២៨៦ អ.យ.ច ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ៖ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ៦៥៧២ "ញ"ដ.ដ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ភក្តី បានឆ្លើយថា នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៩ ម៉ោង ១៨ ខ្លួនបានចូលលុយជាមួយឈ្មោះ [redacted] ធារ៉ាត់ ម្នាក់ ៥០០០ រៀល និងមនុស្សពីរនាក់ទៀតមិនដែលស្គាល់គ្នាពីមុនមកដើម្បីទិញថ្នាំញៀនប្រើប្រាស់ ។ ខ្លួនទិញថ្នាំញៀនបានមួយកញ្ចប់តម្លៃ ២០.០០០ រៀល យកមកប្រើប្រាស់នៅខ្ទមគេទុកចោលជាមួយគ្នា ។ ក្រោយពេលប្រើប្រាស់ថ្នាំញៀនហើយពួកខ្លួននៅអង្គុយនិយាយគ្នាលេងស្រាប់តែសមត្ថកិច្ចចូលមកចាប់ខ្លួន និងដកហូតយកឧបករណ៍ប្រើប្រាស់ថ្នាំញៀនរបស់មនុស្សពីរនាក់ដែលចេញទៅបាត់តែម្តង ។

-ជនជាប់ចោទឈ្មោះ [redacted] ធារ៉ាត់ បានឆ្លើយថា នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៩ ម៉ោង ១៨ ខ្លួនចូលលុយជាមួយឈ្មោះ [redacted] ភក្តី ម្នាក់៥០០០ រៀល ជាមួយមនុស្សពីរនាក់ទៀតមិនដែលស្គាល់គ្នាពីមុនមកដើម្បីទិញថ្នាំញៀនប្រើប្រាស់ ។ ពួកខ្លួនទិញថ្នាំញៀនបានមួយកញ្ចប់តម្លៃ ២០.០០០ រៀល យកមកប្រើប្រាស់នៅខ្ទមគេទុកចោលជាមួយគ្នា ។ ក្រោយពេលប្រើប្រាស់ថ្នាំញៀនហើយពួកខ្លួននៅអង្គុយនិយាយគ្នាលេងស្រាប់តែសមត្ថកិច្ចចូលមកចាប់ខ្លួន និងដកហូតយកឧបករណ៍ប្រើប្រាស់ថ្នាំញៀនរបស់មនុស្សពីរនាក់ដែលចេញទៅបាត់តែម្តង ។

-កំណត់ហេតុទទួលវត្ថុតាង(១) លេខ ៣៦៣៧ រ.វ.ត ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ៖ក្រោយពីបានសួរដេញដោលនាពេលសវនាការជនជាប់ចោទបានឆ្លើយថាខ្លួនពុំបានចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀននោះទេចម្លើយរបស់ជនជាប់ចោទគ្រាន់តែជាចម្លើយដោះសារឱ្យរួចផុតពីការទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនតែប៉ុណ្ណោះ ដូចនេះតំណាង

អយ្យការសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៥២៨៦ អ.យ.ច ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩ ទុកជាបានការដដែល និងសុំឱ្យចៅក្រមជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

-មេធាវីសន្និដ្ឋានការពារជនជាប់ចោទថា កូនក្តីខ្លួនបានចូលលុយគ្នាទិញថ្នាំញៀនមួយកញ្ចប់ដើម្បីប្រើប្រាស់ផ្ទាល់ខ្លួន ពុំមានការចាត់ចែងឱ្យប្រើប្រាស់ដោយសារធាតុញៀនទេ ដូច្នេះសុំតុលាការសម្រេចកែពីបទចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤២ មកបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ កូនក្តីខ្លួនជាអនីតិជន កម្រិតវប្បធម៌ទាប ខ្វះការពិចារណា ដូច្នេះសុំតុលាការអនុវត្តទោសអនីតិជនដល់កូនក្តីខ្លួនផង ។

-ជនជាប់ចោទឈ្មោះ [redacted] ភក្តី និងឈ្មោះ [redacted] ធារ៉ាត់ បាននិយាយសំដីចុងក្រោយបង្អស់ថា៖សុំឱ្យតុលាការជួយបន្ធូរបន្ថយទោស ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានកំណត់ហេតុទទួលវត្ថុតាងនៅដំណាក់កាលអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-តុលាការបានទទួលជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៨០១១ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ ២០១៩ តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ៦៥៧២ "ញ"ដ.ជ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញដែលបានបញ្ជូនជនជាប់ចោទ៖

-ឈ្មោះ [redacted] ភក្តី ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ

-ឈ្មោះ [redacted] ធារ៉ាត់ ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ

ពីបទ ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចខ្ទមទុកចោល ភូមិដើមចាន់ សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញតិមាត្រា៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-ឆ្លងតាមការសួរដេញដោលនាពេលសវនាការឃើញថា នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៩ ម៉ោង ១៨ ជនជាប់ចោទបានចូលលុយគ្នាម្នាក់ ៥.០០០ រៀល ជាមួយមនុស្សពីរនាក់ទៀតមិនដែលស្គាល់គ្នាពីមុនមកដើម្បីទិញថ្នាំញៀនប្រើប្រាស់ ។ ពួកខ្លួនទិញថ្នាំញៀនបានមួយកញ្ចប់តម្លៃ ២០.០០០ រៀល យកមកប្រើប្រាស់នៅខ្ទមគេទុកចោលជាមួយគ្នា ។ ក្រោយពេលប្រើប្រាស់ថ្នាំញៀនហើយពួកខ្លួននៅអង្គុយនិយាយគ្នាលេងស្រាប់តែសមត្ថកិច្ចចូលមកចាប់ខ្លួន និងដកហូតយកឧបករណ៍ប្រើប្រាស់ថ្នាំញៀនរបស់មនុស្សពីរនាក់ដែលចេញទៅបាត់តែម្តង ។

៣-នៅពេលឃាត់ខ្លួនជនជាប់ចោទសមត្ថកិច្ចដកហូតវត្ថុតាងនូវ ឧបករណ៍សម្រាប់ប្រើប្រាស់ថ្នាំញៀនដែលវត្ថុតាងនេះមានភាពស៊ីសង្វាក់ជាមួយចម្លើយសារភាពរបស់ជនជាប់ចោទថាពួកខ្លួន បានប្រើប្រាស់ជាមួយ



Scanned with CamScanner

មនុស្សពីរនាក់ទៀតមិនស្គាល់ ដូច្នេះអាចបញ្ជាក់បានថាជនជាប់ចោទពិតជាបានរៀបចំចាត់ចែងដើម្បីឱ្យអ្នកដទៃប្រើប្រាស់ថ្នាំញៀនពិតប្រាកដមែន ។

៤-តាមចម្លើយជនជាប់ចោទ និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងភស្តុតាងផ្សេងៗដែលមាននៅក្នុងសំណុំរឿង មានលក្ខណៈស៊ីសង្វាក់បញ្ជាក់បានថាជនជាប់ចោទឈ្មោះ [redacted] ភក្តី និងឈ្មោះ [redacted] ធារ៉ាត់ ពិតជាបានប្រព្រឹត្តបទល្មើស ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចខ្ទមទុកចោល ភូមិដើមចាន់ សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញតិមាត្រា៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ពិតមែន។

៥-សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ភក្តី និងឈ្មោះ [redacted] ធារ៉ាត់ ដែលចាត់ចែងឱ្យសម្រួលឱ្យអ្នកដទៃប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ត្រូវបានច្បាប់កំណត់ថា ជាបទល្មើស **ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ហើយបញ្ញតិឱ្យផ្តន្ទាទោសដាក់ពន្ធនាគារពី **២(ពីរ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ** ពិន័យជាប្រាក់ពី៤.០០០.០០០(បួនលាន)រៀល ទៅ១០.០០០.០០០ (ដប់លាន)រៀល តាមមាត្រា ៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៦-អំពើរបស់ជនជាប់ចោទធ្វើឱ្យប៉ះពាល់ដល់សុខភាពអ្នកដទៃ សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសង្គមដែលកំណត់ជាបទល្មើសតាមបញ្ញត្តិមាត្រា៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៧-ជនជាប់ចោទឈ្មោះ [redacted] ភក្តី និងឈ្មោះ [redacted] ធារ៉ាត់ ជាអនីតិជន និងជាជនដែលមាន នីតិសម្បទាស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ។

៨-ការលើកឡើងរបស់តំណាងអយ្យការក្នុងសេចក្តីសន្និដ្ឋាននាពេលសវនាការដោយបានលើកឡើងភស្តុតាងបញ្ជាក់ពីពិរុទ្ធភាពលើជនជាប់ចោទពីបទ**ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**មានលក្ខណៈត្រឹមត្រូវតាមច្បាប់។

៩-មេធាវីសន្និដ្ឋានការពារថា កូនក្តីខ្លួនគ្រាន់តែប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនទេ គឺមិនបានចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនទេ ។ តុលាការយល់ឃើញថាពុំមានភាពត្រឹមត្រូវតាមអង្គហេតុដែលបានកើតឡើងទេ ព្រោះនៅពេលសមត្ថកិច្ចឃាត់ខ្លួនជនជាប់ចោទបានរកឃើញឧបករណ៍ប្រើប្រាស់ថ្នាំញៀន ហើយជនជាប់ចោទបានឆ្លើយថាជារបស់មនុស្សពីរនាក់ផ្សេងទៀតបានចេញទៅបាត់ហើយ ដូច្នេះ មានន័យថាអ្នកទាំងពីរដែលចេញទៅបាត់នោះបានប្រើប្រាស់ថ្នាំញៀនរួចបាត់ហើយ ដែលស៊ីសង្វាក់បញ្ជាក់បានថាឈ្មោះ [redacted] ភក្តី និងឈ្មោះ [redacted] ធារ៉ាត់ បានចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនពិត មែន ។

១០-ជនជាប់ចោទនិយាយសំដីចុងក្រោយបង្អស់ថា៖ សុំឱ្យតុលាការជួយបន្ធូរបន្ថយទោសឱ្យខ្លួនផងគប្បីតុលាការពិចារណាលើសំណូមពរនេះ។

១១-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ភក្តី និងឈ្មោះ [redacted] ធារ៉ាត់ ពីបទចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅ ចំណុចខ្ទមទុកចោល ភូមិដើមចាន់ សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញតិមាត្រា៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។



Scanned with CamScanner

១២-តុលាការនឹងប្រកាសទោសលើជនជាប់ចោទឈ្មោះ [redacted] ភក្តី និងឈ្មោះ [redacted] ផារ៉ាត់ តាមបញ្ញត្តិមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ដោយសារជនជាប់ចោទជាអនីតិជនអាយុលើស១៤ឆ្នាំ ។

១៣-តាមកំណត់ហេតុទទួលវត្ថុចាប់យក(១) លេខ ៣៦៣៧ រ.វ.ត ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញមានឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយកំប្លេរ គប្បីសម្រេចរឹបអូសតាមមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១៤-តុលាការនឹងប្រកាសទោសដាក់ពន្ធនាគារលើសអប្បបរមានៃទោសចំពោះជនជាប់ចោទឈ្មោះ [redacted] ភក្តី និងឈ្មោះ [redacted] ផារ៉ាត់ តុលាការពិចារណាក្នុងការប្រកាសឱ្យព្យួរការអនុវត្តទោសមួយផ្នែក ដើម្បីទុកឱកាសឱ្យជនជាប់ចោទបានកែប្រែខ្លួន ដោយជនជាប់ចោទបានសារភាពកំហុសរបស់ខ្លួន ហើយជនជាប់ចោទទើបតែ ប្រព្រឹត្តបទល្មើសដែលត្រូវតុលាការផ្តន្ទាទោសជាលើកទី១ ហើយទោសដែលនឹងប្រកាសមានរយៈពេលមិនលើសពី ០៥ (ប្រាំ) ឆ្នាំ យោងតាមមាត្រា ១០៤-១០៨ នៃក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច

I-ផ្តន្ទាទោស:

១.ឈ្មោះ [redacted] ភក្តី ហៅ អ៊ុយ ភេទប្រុស អាយុ ១៧ឆ្នាំ ជាតិខ្មែរ មុខរបរ កម្មករសំណង់ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកណ្តាល នៅលីវ ឪពុកឈ្មោះ [redacted] ទូច "ស្លាប់" ម្តាយឈ្មោះ [redacted] តុង "រស់" ជានីតិជន ទោសពីមុន គ្មាន ។

ដាក់ពន្ធនាគារកំណត់ ០១ (មួយ) ឆ្នាំ

ទោសពន្ធនាគារដែលប្រកាសខាងលើត្រូវអនុវត្តដូចខាងក្រោម:

**-អនុវត្តទោសពន្ធនាគារ ០៦ (ប្រាំមួយ) ខែ ។**

-ទោសពន្ធនាគារដែលនៅសល់ត្រូវព្យួរការអនុវត្តតាមបញ្ញត្តិមាត្រា ១០៤-១០៨ នៃក្រមព្រហ្មទណ្ឌ ។

២.ឈ្មោះ [redacted] ផារ៉ាត់ ហៅ អ៊ុយ ភេទប្រុស អាយុ ១៧ឆ្នាំ ជាតិខ្មែរ មុខរបរ កម្មករសំណង់ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្ននៅភូមិព្រែកដាច់ ឃុំព្រែកតូច ស្រុកលើកដែក ខេត្តកណ្តាល នៅលីវ ឪពុកឈ្មោះ [redacted] ស៊ីន "រស់" ម្តាយឈ្មោះ [redacted] សាវង់ "រស់" ជានីតិជន ទោសពីមុន គ្មាន ។

ដាក់ពន្ធនាគារកំណត់ ០១ (មួយ) ឆ្នាំ

ទោសពន្ធនាគារដែលប្រកាសខាងលើត្រូវអនុវត្តដូចខាងក្រោម:

**-អនុវត្តទោសពន្ធនាគារ ០៦ (ប្រាំមួយ) ខែ ។**

-ទោសពន្ធនាគារដែលនៅសល់ត្រូវព្យួរការអនុវត្តតាមបញ្ញត្តិមាត្រា ១០៤-១០៨ នៃក្រមព្រហ្មទណ្ឌ ។

ពីបទ **ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅ ចំណុចខ្ទមទុកចោលភូមិដើមចាន់ សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញតិមាត្រា៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

II-វត្ថុតាងដែលត្រូវរឹបអូស ឧបករណ៍សម្រាប់ប្រើប្រាស់គ្រឿងញៀនមួយកំប្លេរ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទ ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ ។

*សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលក្រម ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកម្លាំងប្រដាប់អាវុធជួយសហការអនុវត្តសាលក្រមនេះ ឱ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។*

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខា និងត្រា |
| [redacted] | | | |

---

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ៣កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner